# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
## គម្រោងបញ្ចប់ផែនការ
## កំណែលើកទី ១៧
## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨


**សេចក្តីសង្ខេប** .......... 2
I. **សេចក្តីផ្តើម** .......... 3
II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 6
III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 8
  ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត .......... 8
  ខ. អង្គបុរេជំនុំជម្រះ .......... 10
IV. **ផែនការបញ្ចប់សវនាការ** .......... 11
  ក. សំណុំរឿង០០២/០២ .......... 12
  ខ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 14
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 14
  ក. សំណុំរឿង០០២/០២ .......... 14
  ខ. សំណុំរឿង០០៣ និងសំណុំរឿង០០៤ .......... 14
VI. **សេចក្តីសន្និដ្ឋាន** .......... 14


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**សម្គាល់៖**
គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយ មិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើពេលវេលាដែលព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាល ដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ១៧ នៃ គម្រោងបញ្ចប់ផែនការនេះ ដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

នៅក្នុងអំឡុងត្រីមាសនេះ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ ទាក់ទងនឹង អ៊ឹម ចែម ដោយបានតម្កល់សេចក្តីសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត។ កិច្ចដំណើរការនីតិវិធីតុលាការក្នុងរឿងក្តីនេះ បច្ចុប្បន្នត្រូវបានបញ្ចប់។ អង្គជំនុំជម្រះសាលាដំបូងបន្តពិភាក្សាសម្រេចអំពីសាលក្រម និងធ្វើសេចក្តីព្រាងសាលក្រមក្នុងសំណុំរឿង០០២/០២។

គម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

## I. សេចក្តីផ្តើម

1 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[1]។

2 គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឱ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី១៧ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

3 ឯកសារនេះផ្តោតជាពិសេសលើការវិវត្តនាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[2]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

4 សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ *ឌុច*) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឱ្យសំណុំរឿងនេះត្រូវបានបញ្ចប់ជាស្ថាពរ។ កាំង ហ្គេចអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

5 អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួន២ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា នឹង ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំសេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុត នៃសហឧក្រិដ្ឋកម្មរួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល និងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្តន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

6 ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជំម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹទ្ធលើពុទ្ធសាសនិក) ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និង បទបញ្ជោស្តីពីការរៀបអាពាហ៍ពិពាហ៍។ សវនាការលើអង្គហេតុបានចាប់ផ្តើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការចំនួន២៧៤ថ្ងៃ និងស្តាប់សក្ខីកម្មសាក្សីចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន៨នាក់។ ភាគីបានដាក់សារណាបិទកិច្ចពិភាក្សាដេញដោលរបស់ខ្លួននៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើទាមទារសំណងចុងក្រោយរបស់ខ្លួននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ និងសេចក្តីសន្និដ្ឋានបន្ថែមលើបញ្ជាថវិកានៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ បច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងពិភាក្សាសម្រេចអំពីសាលក្រមរបស់ខ្លួន និងធ្វើសេចក្តីព្រាងសាលក្រមដោយមានសំអាងហេតុ ដែលសាលក្រមនេះរំពឹងថានឹងចេញនៅត្រឹម ត្រីមាសទី៤ ឆ្នាំ២០១៨។

7 នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

8 ស្ថានភាពនៃការស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ មានដូចខាងក្រោម៖

ក- នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយដោយមានសម្អាងហេតុពេញលេញលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍លើយុត្តាធិការបុគ្គល រួមបញ្ចូលទាំងកិច្ចដំណើរការនីតិវិធីតុលាការនៅក្នុងរឿងក្តីនោះ។ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញពុំមានយុត្តាធិការលើ អ៊ឹម ចែម ត្រូវបានតម្កល់។

ខ- នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជូនសំណុំរឿង០០៣ ទៅការិយាល័យសហព្រះរាជអាជ្ញាពិនិត្យដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរនៅខែវិច្ឆិកា។ ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ត្រូវបានដាក់នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះ រំពឹងថានឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៨។

គ- នៅថ្ងៃទី១៨ និង២១ ខែសីហា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានទទួលដីកា សន្និដ្ឋានស្ថាពរចំនួនពីរក្នុងសំណុំរឿង០០៤/០២ ពីសហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ។ នៅថ្ងៃទី៣០ ខែតុលា សហចៅក្រមស៊ើបអង្កេតបានទទួលចម្លើយតបរបស់មេធាវីការពារក្តី។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងថានឹងចេញនៅត្រីមាសទី៣ ឆ្នាំ២០១៨។

ឃ- នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៤ ត្រូវបានបញ្ចប់ជាលើកទី២ ក្រោយពីដោះស្រាយសំណើបន្ថែមជាច្រើនពីភាគី។ សំណុំរឿងនេះត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨។ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ចំណែក សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។ ដីកាដំណោះស្រាយនៅក្នុងរឿងក្តីនេះរំពឹងថា នឹងចេញនៅក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០១៩។

9 ក្នុងអំឡុងពេលត្រីមាសនេះ បានសម្រេចនូវព្រឹត្តិការណ៍សំខាន់មួយ ដោយការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ ទាក់ទងនឹង អ៊ឹម ចែម។ កិច្ចដំណើរការនីតិវិធីតុលាការក្នុងរឿងក្តីនេះបានបិទបញ្ចប់ ដោយមានសេចក្តីសម្រេចស្ថាពររបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។

10 តាមរយៈការវិវត្តក្នុងត្រីមាសនេះ គម្រោងបញ្ចប់ផែនការនេះកំណត់ព្រឹត្តិការណ៍សំខាន់ៗដែលនៅសេសសល់ចំនួន៩ សម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៨)។

(ii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៩) និង

(iii) ចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមានបណ្តឹងសាទុក្ខ (ត្រីមាសទី៣ ឆ្នាំ២០២០)។

11 នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤ សំណុំរឿង០០៤/០១ និងសំណុំរឿង០០៤/០២ ព្រឹត្តិការណ៍ដាច់ដោយឡែកត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរ ដែលនៅសេសសល់ ហើយ ក្នុងករណី

មានការចោទប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[3]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(iv) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេច ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៨)។

(v) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៣ ឆ្នាំ២០១៩) ។

(vi) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៩)។

(vii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០២០)។

(viii) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤/០២ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៨)។ និង

(ix) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០១៩)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការធានឆាប់រហ័ស

12 ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅ ត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិធ្វើកូដកម្មមិនធ្វើការចំនួនពីរលើកក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-២០១៧ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកា និងធ្វើឲ្យមានការផ្តោតម្តូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

13 ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេច កំណត់ទឹកប្រាក់ចំនួនមិនលើសពី ៨ លានដុល្លារ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក. សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អ.វ.ត.ក. មិនឲ្យរអាក់រអួលក្នុងកំឡុង៦ខែ ដំបូងនៃឆ្នាំ២០១៨ ” ដោយបើកឱកាសឲ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់វិភាគទាន

[3] ដីកាដំណោះស្រាយនឹងបញ្ជាក់ថានឹងមានការចោទប្រកាន់ឬទម្លាក់ការចោទប្រកាន់។ ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

ដោយផ្ទាល់ ចំនួន៤,០លានដុល្លារ ដូចដែលបានធ្វើនៅក្នុងឆ្នាំ២០១៧ ដើម្បីចំណាយទៅលើប្រាក់បៀវត្សរ៍បុគ្គលិកជាតិ ៦ខែ ដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៨ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃ អ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការ ទាំងនេះធានាថា ដំណាក់កាលដែលមានទំហំការងារច្រើនបំផុត បច្ចុប្បន្ននៅក្នុងកិច្ចការរបស់ អ.វ.ត.ក. បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ច។ វិភាគទានស្ម័គ្រចិត្ត តាមការប៉ាន់ប្រមាណគឺ មានចំនួន ១១ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ១,៣៦ លានដុល្លារ សម្រាប់ភាគីជាតិ ដោយប្រៀបទៅនឹងគម្រោងថវិកាដែលបានអនុម័តរួចហើយចំនួន ១៨,៨៩ លាន ដុល្លារ[4] សម្រាប់ភាគីអន្តរជាតិ និង ៥,៧៩ លានដុល្លារសម្រាប់ភាគីជាតិក្នុងឆ្នាំ២០១៨។ ក្នុងតួលេខនេះ ភាគីអន្តរជាតិបានទទួលទឹកប្រាក់ចំនួន ៤,៣៥ លានដុល្លារ ហើយភាគីជាតិទទួលបាន ចំនួន ០,១៣ មកដល់ពេលនេះ។ ចំនួនតុល្យការរំពឹងថានឹងទទួលបាននៅកំឡុងឆ្នាំនេះ។ កិច្ចខិតខំប្រឹងប្រែងកៀរគរថវិកាកំពុងតែបន្តធ្វើដើម្បីទទួលបានចំនួនថវិកាបន្ថែមទៀត។

14 ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោមត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថា កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនឹងមិនត្រូវរំខានដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើងម្តងទៀត យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

15 នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក. បានអនុម័តវិសោធនកម្មទៅលើវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយវិសាលភាពកិច្ចស៊ើបសួរ ដរាបណាវិសាលភាពស៊ើបសួរដែលបានកាត់បន្ថយនោះជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ តាមការចោទប្រកាន់[5]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាព នៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជំនុំជម្រះនោះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[6]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូលនៅក្នុង សំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ការសម្រេចសេចក្តីចុងក្រោយនៃ សំណុំរឿង ០០២/០២ នឹងបញ្ចប់នូវកិច្ចនីតិវិធីសំណុំរឿង០០២ តែម្តង។

16 ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ក្នុងពេលពាក់ព័ន្ធ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយ ដែលកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេត។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលអត្ថប្រយោជន៍ពីបុគ្គលិកដែលមានគុណវឌ្ឍិបន្ថែមក្រោមកម្មវិធីឥតសំណង និងកម្មសិក្សាការីបន្ថែមទៀតដែលបានបែងចែកជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ ការណ៍នេះបានបង្កើនសមត្ថភាពស៊ើបអង្កេតបានកាន់តែលឿន។ ជាងនេះទៀត ការិយាល័យរដ្ឋបាលបានជួលសេវាកម្មបកប្រែភាសាពីបុគ្គលិកឯកទេសបន្ថែមទៀត ដើម្បីគាំទ្រដល់ការិយាល័យតុលាការ ដើម្បីធានាបាននូវសេវាបកប្រែភាសា និងប្រតិចារឹកបានទាន់ពេលវេលា។

---

[4] ថវិកាសុទ្ធចំនួន៤៣.០០០ដុល្លារដែលបានលៃលកសម្រាប់គ្រឿងសង្ហារិម និងសម្ភារផ្សេងៗ ដកចេញសម្រាប់ភាគីអន្តរជាតិស្របតាមកថាខណ្ឌ៣១នៃរបាយការACABQ (A/72/7/Add.7)។

[5] វិធាន៦៦ស្ទួន អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតដកចេញអង្គហេតុជាក់លាក់មួយចំនួនពីការស៊ើបអង្កេតដរាបណាអង្គ ហេតុដែលនៅសល់អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ សេចក្តីសម្រេចប្រើវិធាន៦៦ស្ទួនគឺតម្រូវដោយច្បាប់ដែលនឹងធ្វើនៅដំណាក់កាលជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ។

[6] វិធាន៨៩*ស្ទួនបី*។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

17 កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើងក្រោយពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៩ ហើយក្រោយពីដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយចំនួនទៀត សំណុំរឿង០០៤ ក៏ត្រូវបំបែកទៅជាសំណុំរឿងចំនួន៣ ពោលគឺ៖ សំណុំរឿង០០៤/០១ ពាក់ព័ន្ធ អ៊ឹម ចែម សំណុំរឿង០០៥/០២ ពាក់ព័ន្ធ អោ អាន និង សំណុំរឿង០០៤ ប្រឆាំងនឹង យឹម ទិត្យ។ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

### ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

18 ក្នុងអំឡុងកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ មានការចុះបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុចំនួន ២៦៩ លើក និងធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១៤១១ នាក់។ បេសកកម្មស៊ើបអង្កេតគ្រប់សំណុំរឿងទាំងអស់ត្រូវបានបញ្ចប់ហើយ។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង ២៥០០ កំពុងត្រូវបានពិនិត្យដើម្បីរៀបចំសេចក្តីសម្រេចទទួលស្គាល់ ឬបដិសេធ ហើយនៅសល់តែកិច្ចការធ្វើបច្ចុប្បន្នភាពតែប៉ុណ្ណោះដែលនៅសេសសល់។

19 ដំណើរការវិវត្តទៅមុខនៃសំណុំរឿងទាំងអស់គឺនៅតែអាស្រ័យជាចម្បងទៅលើថវិកាគ្រប់គ្រាន់ បុគ្គលិកគ្រប់គ្រាន់ ការជ្រើសរើសបុគ្គលិកទាន់ពេលវេលាសម្រាប់តំណែងដែលទំនេរ និង ការបកប្រែឯកសារបានឆាប់រហ័ស។ ចម្លើយតប ឬរយៈពេលបណ្តឹងឧទ្ធរណ៍ណាមួយ ចាប់ផ្តើមតែនៅពេលដែលសំណៅជាភាសាខ្មែរនៃឯកសារត្រូវបានជូនដំណឹងប៉ុណ្ណោះ។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតជាតិ និងក្រុមការងាររបស់គាត់ធ្វើការជាចម្បងតែជាមួយសំណៅជាភាសាខ្មែរនៃឯកសារណាមួយដែលបានដាក់។ ដើម្បីបញ្ជាក់បញ្ហានេះឱ្យបានច្បាស់ វាមានសារៈសំខាន់ក្នុងការបង្ហាញថា អង្គភាពបកប្រែភាសារបស់តុលាការ បានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិតាមអ៊ីមែលចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ ថា ដោយផ្អែកលើឧបសគ្គខាងភស្តុភារ និងបុគ្គលិក ការបកប្រែភាសាពីអង់គ្លេសទៅខ្មែរ និងការពិនិត្យផ្ទៀងផ្ទាត់ ជាមធ្យម[7]ត្រូវចំណាយពេលប្រហែល ៨ សប្តាហ៍ សម្រាប់ ៣០០ ទំព័រ និង ១២ សប្តាហ៍ សម្រាប់ ៥០០ ទំព័រ។ ការថមថយបុគ្គលិកផ្នែកភាគីអន្តរជាតិនៃការិយាល័យនេះ បានប្រែក្លាយពីក្តីកង្វល់ពិតប្រាកដ ទៅជាការពិតជាក់ស្តែងដែលគួរឱ្យបារម្ភ និងបានកើតឡើងដល់កម្រិតមិនធ្លាប់មាននៅឆ្នាំចុងក្រោយនេះ។ កិច្ចសន្យាការងាររយៈពេលខ្លីជាបន្តបន្ទាប់ដែលមិនគួរឱ្យចង់បាន បានក្លាយជានិយាមក្នុងរយៈពេលឆ្នាំចុងក្រោយនេះ ដែលនាំឱ្យមានការលំបាកក្នុងការរក្សាបុគ្គលិក៖ ក្នុងរយៈពេលចាប់ពីខែមិថុនា ឆ្នាំ២០១៧ ដល់ចុងខែមិថុនា ឆ្នាំ២០១៨ ផ្នែកភាគីអន្តរជាតិបានបាត់បង់បុគ្គលិក និងទីប្រឹក្សាការងារចំនួន ១៣ នាក់ តាមរយៈការសុំលាឈប់ពីមុខតំណែង ចំនួន ១០ នាក់ចាប់តាំងពីខែមិថុនា ឆ្នាំ២០១៧ តែឯង ដែលការណ៍នេះនាំឱ្យមានតម្រូវការនីតិវិធីជ្រើសរើសបុគ្គលិកជាច្រើន និងដែលចំណាយពេលច្រើន។ ដូច្នេះ ជាមធ្យម ការិយាល័យនេះបានបាត់បង់បុគ្គលិកម្នាក់ក្នុងមួយខែ។ ការផ្គត់ផ្គង់បុគ្គលិកនៃការិយាល័យនេះបច្ចុប្បន្នកាន់តែស្តួចស្តើងខ្លាំង ដែលសូម្បីតែការលាឈប់របស់បុគ្គលិកដ៏តិចតួច ក៏អាចប៉ះពាល់ខ្លាំងដល់សមត្ថភាពរួមរបស់ការិយាល័យនេះ និងលទ្ធភាពរបស់ខ្លួនក្នុងអនុវត្តតាមតារាងកំណត់ពេលវេលាដែលបានគ្រោងទុក (សូមមើលខាងក្រោម) ជាពិសេស នៅដំណាក់កាលចុងក្រោយនៃការស៊ើបអង្កេត[8]។

[7] អង្គភាពបកប្រែភាសា នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ បានបញ្ជាក់ថា ការប៉ាន់ស្មាននេះអាចប្រែប្រួល អាស្រ័យលើខ្លឹមសារជាក់ស្តែងនៃឯកសារ នៅពេលដាក់។

[8] នៅពេលដែលការស៊ើបអង្កេតកំពុងដំណើរការ បុគ្គលិក(ច្បាប់)ថ្មី មានរយៈពេលបន្ថែមមួយរយៈខ្លី ដោយសារតែការព្រាងដីកាដំណោះស្រាយមិនទាន់បានចាប់ផ្តើមក្នុងកម្រិតដូចគ្នា ទោះជាយ៉ាងណា ពេលនេះការបាត់បង់បុគ្គលិកណាម្នាក់ និងការជ្រើស

20 គិតត្រឹមចុងបញ្ចប់នៃត្រីមាសនេះ សំណុំរឿងស្ថិតក្នុងស្ថានភាពដូចខាងក្រោម៖

ក. ក្នុងសំណុំរឿង ០០៣ ចម្លើយតបចំនួន ៣១៨ ទំព័រ ជាភាសាអង់គ្លេសពីមេធាវីការពារក្តីឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញា ត្រូវបានដាក់នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨ ការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយបានកំពុងដំណើរការមួយរយៈហើយ ប៉ុន្តែមិនទាន់អាចបញ្ចប់មុនពេលសំណៅបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់មេធាវីការពារក្តីបានទេ ដែលចម្លើយតបនេះរំពឹងថានឹងដាក់ដោយអង្គភាពបកប្រែភាសានៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៨។ ជាងនេះទៀត បុគ្គលិកសំខាន់ដែលបានធ្វើការងារនេះយូរមកហើយ និងដែលជាអ្នកសម្របសម្រួលដំណើរការធ្វើសេចក្តីព្រាងប្រចាំថ្ងៃនៅក្នុងរឿងក្តីនេះ បានលាឈប់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ដែលការណ៍នេះបូករួមនឹងពេលវេលាដែលត្រូវការដើម្បីជ្រើសរើសបុគ្គលិកថ្មី ដើម្បីបំពេញកាងារនេះ និង/ឬ បែងចែកការងារនេះក្នុងចំណោមសមាជិកក្រុមដែលនៅសល់ មានន័យថាតារាងពេលវេលាកំណត់នេះត្រូវបានប៉ះពាល់យ៉ាងខ្លាំង។ ផ្អែកលើផលប៉ះពាល់ជារួមនៃកង្វះខាតបុគ្គលិក និងធនធានបកប្រែរបស់អង្គភាពបកប្រែភាសាដែលបានព្យាករ តារាងកំណត់ពេលវេលានេះត្រូវបានរំកិលទៅត្រីមាសទីបួន ឆ្នាំ២០១៨។ ញត្តិសុំមោឃភាពមួយដែលដាក់ដោយភាគីការពារក្តី នៅខែកក្កដា ឆ្នាំ២០១៧ កំពុងស្ថិតនៅចំពោះមុខ អ.ប.ជ. នៅឡើយ នៅពេលសរសេររបាយការណ៍នេះ។

ខ. សំណុំរឿង០០៤/០២ ស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការធ្វើដីកាដំណោះស្រាយ ប៉ុន្តែការលាឈប់របស់បុគ្គលិកសំខាន់ៗនាពេលថ្មីៗនេះនៅខាងភាគីអន្តរជាតិ បានធ្វើឱ្យមានការពន្យារពេលដល់ត្រីមាសទីបី ឆ្នាំ២០១៨ ដែលចាំបាច់តាមកំណែប្រែផែនការបញ្ចប់ការងារពីមុន។ បុគ្គលិកកម្រិត P-3 ដ៏សំខាន់ម្នាក់នៃក្រុមសំណុំរឿង ០០៤/០២ ដែលទទួលបន្ទុកដោះស្រាយ និងធ្វើបច្ចុប្បន្នភាពពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅគ្រប់សំណុំរឿង បានលាឈប់ និងបានចាកចេញនៅពាក់កណ្តាលខែមេសា ឆ្នាំ២០១៨។ សមាជិកទីពីរនៃក្រុមសំណុំរឿង ០០៤/០២ ដែលធ្វើការនៅទីកន្លែងផ្ទាល់ជាបុគ្គលិកប្រឹក្សា បានលាឈប់នៅចុងខែមីនា ឆ្នាំ២០១៨ ដោយសារបញ្ហាគ្រួសារ ដែលត្រូវត្រឡប់ទៅកាន់អឺរ៉ុបវិញ ហើយគាត់ត្រូវបានជួលឡើងវិញបន្ទាប់ពីឆ្លងកាត់ដំណើរការជ្រើសរើសបុគ្គលិក ជាបុគ្គលិកប្រឹក្សាបំពេញការងារពីចម្ងាយ ហើយគាត់នឹងបញ្ចប់កិច្ចសន្យាការងាររបស់គាត់នៅខែកក្កដា ឆ្នាំ២០១៨។ ការលាឈប់ពីមុខតំណែងទាំងពីរនេះ រួមជាមួយនឹងនីតិវិធីជ្រើសរើសបុគ្គលិកដ៏លំបាក បាននាំឱ្យមានការបាត់បង់សមត្ថភាពក្នុងការធ្វើសេចក្តីព្រាង។ បុគ្គលិកប្រឹក្សាម្នាក់ទៀតដែលធ្វើការលើការគាំទ្រច្បាប់នីតិវិធីជាទូទៅ នៃសំណុំរឿង ០០៤/០២ (និងសម្រាប់សំណុំរឿង០០៣ និង ០០៤) នឹងធ្វើការត្រួតគ្នាជាក្រឡាបញ្ជីរងនៃការិយាល័យនេះ បានលាឈប់ពីមុខតំណែងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨។ តារាងកំណត់ពេលវេលា សម្រាប់សំណុំរឿង ០០៤/០២ ដែលបានផ្តល់ក្នុងកំណែប្រែលើកទី១៦ នៃផែនការនេះ ពោលគឺ នៃត្រីមាសទីបី ឆ្នាំ២០១៨ បច្ចុប្បន្ននៅតែមានបច្ចុប្បន្នភាព ដោយសន្មតថាការបកប្រែដីកាដំណោះស្រាយនឹងត្រូវបញ្ចប់ផងដែរដោយអង្គភាពបកប្រែភាសា នៅក្នុងត្រីមាសនោះ។

គ. ក្នុងសំណុំរឿង០០៤ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ទាំងភាសាអង់គ្លេស (១១ ទំព័រ) និងភាសាខ្មែរ (១៥ ទំព័រ)។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនចំនួន ៧៣២ ទំព័រ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ដោយសារតែឧបសគ្គផ្នែកធនធាន គាត់មិនអាចដាក់ដំណាលគ្នាជាភាសាខ្មែរក្នុងរយៈពេលបីខែ ដែលកំណត់ដោយវិធានផ្ទៃក្នុងបានទេ។ ការងារធ្វើដីកាដំណោះស្រាយចុងក្រោយ អាចចាប់ផ្តើមបានតែនៅពេលណាមេធាវីការពារក្តីបានដាក់ចម្លើយតបរបស់ខ្លួនប៉ុណ្ណោះ ដែលនឹងជារយៈពេល ៣ ខែ បន្ទាប់ពីការបកប្រែជាភាសាខ្មែរនៃសារណារបស់ ស.ព.អ. ត្រូវបាន

---

រើសបុគ្គលិកថ្មី គឺជាការបាត់បង់ពេលវេលា និងសមត្ថភាពធ្វើសេចក្តីព្រាង។ និយាយម្យ៉ាងទៀត ផលប៉ះពាល់លើតារាងពេលវេលាកំណត់នៃដីកាដំណោះស្រាយ ពេលនេះមានលក្ខណៈផ្ទាល់ និងបន្ទាន់។

ជូនដំណឹង ដែលរំពឹងថានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ដោយផ្អែកលើការកែប្រែការប៉ាន់ស្មានរបស់អង្គភាពបកប្រែភាសាថាការបកប្រែជាភាសាខ្មែរនឹងបញ្ចប់នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨។ ឧបសគ្គផ្នែបុគ្គលិកក៏ប៉ះពាល់ធ្ងន់ធ្ងរដល់ក្រុមរបស់គាត់ផងដែរ៖ សមាជិកម្នាក់ក្នុងចំណោមសមាជិកពីរនាក់ដែលនៅសល់ ដែលជាបុគ្គលិកប្រឹក្សាដែលមានចំណេះដឹងអំពីរឿងក្ដីយូរណាស់មកហើយបានលាឈប់នៅចុងខែមិថុនា ឆ្នាំ២០១៨។ ផលប៉ះពាល់ពិតប្រាកដនៃការបាត់បង់ ៥០% នៃសមត្ថភាពក្រុមនេះ ទៅលើវឌ្ឍភាពនៃការធ្វើសេចក្ដីព្រាងនៅមិនទាន់ដឹងច្បាស់នៅឡើយទេ។ ដោយយោងទៅលើភាពស្មុគស្មាញនៃរឿងក្ដី[9] ធនធានបកប្រែភាសា និងការបាត់បង់បុគ្គលិក ទោះជាយ៉ាងណាការបញ្ចប់សេចក្ដីព្រាង និងការបកប្រែភាសា ពេលនេះមិនទាន់អាចព្យាករបានទេ រហូតដល់ត្រីមាសទី១ នៃឆ្នាំ២០១៩។ ដោយសារតែកំណែប្រែនៃផែនការបិទបញ្ចប់នេះត្រូវបានធ្វើឡើងក្នុងគោលបំណងជាមូលដ្ឋានសម្រាប់សំណើសុំថវិកាចុងក្រោយពី ក.ស.ច.ស. នោះ ហានិភ័យជាបន្តបន្ទាប់នៃការបាត់បង់បុគ្គលិកបន្តទៀតតម្រូវឱ្យប្រើការវាយតម្លៃដ៏ប្រុងប្រយ័ត្នពីហានិភ័យទាំងនេះ ហើយដូច្នេះតារាងកំណត់ពេលវេលាត្រូវបានរំកិលទៅត្រីមាសទីពីរ ឆ្នាំ២០១៩ បើទោះបីជានឹងមានការខិតខំប្រឹងប្រែងបញ្ចប់វាឱ្យបានឆាប់ជាងនេះក្ដី។ ញត្តិស្នើសុំមោឃភាពចំនួនពីរដែលដាក់ដោយមេធាវីការពារក្ដីក្នុងខែកញ្ញា និងវិច្ឆិកា ឆ្នាំ២០១៧ នៅកំពុងរង់ចាំដំណោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះនៅឡើយ នៅពេលសរសេររបាយការណ៍នេះ។ ប្រសិនបើ អ.ប.ជ. សម្រេចមោឃៈភ័ស្តុតាងមួយចំនួនចោល នោះភាគីនឹងមានឱកាសលើកឡើងបញ្ហានេះ ក្នុងកម្រិតមួយតាមការចាំបាច់។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ មេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលការបកប្រែសេចក្ដីសម្រេចនេះ ទើបតែបានជូនដំណឹងនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៨ ប៉ុណ្ណោះ។

21 កត្តាទាំងឡាយដែលបានរៀបរាប់ខាងលើ ជាលទ្ធផលគឺនាំឱ្យការព្យាករណ៍ចេញដីកាដំណោះស្រាយដូចខាងក្រោម (តារាងកំណត់ពេលវេលាមិនអាច និងមិនគួរចាត់ទុកជាអ្វីឱ្យលើសពីការព្យាករណ៍នោះឡើយ ទោះជាក្នុងករណីណាក៏ដោយ)៖

ក. ក្នុង*សំណុំរឿង០០៣* ត្រឹមត្រីមាសទី៤ ឆ្នាំ២០១៨។

ខ. ក្នុង*សំណុំរឿង០០៤* ត្រឹមត្រីមាសទី២ ឆ្នាំ ២០១៩។

ឃ. ក្នុង*សំណុំរឿង០០៤/០២* ត្រឹមត្រីមាសទី៣ ឆ្នាំ២០១៨។

## ***ខ. អង្គបុរេជំនុំជម្រះ***

22 ក្នុងត្រីមាសទី២ ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះសម្រេចបានព្រឹត្តិការណ៍សំខាន់មួយ តាមរយៈការចេញសេចក្ដីពិចារណាជាសាធារណៈរបស់ខ្លួន លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/០១ ក៏ដូចជា សេចក្ដីសម្រេចមួយលើបណ្ដឹងឧទ្ធរណ៍ និងសេចក្ដីសម្រេចបីលើសំណើសុំទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឡើងវិញឱ្យទៅជាសាធារណៈនូវឯកសារតុលាការ ក្នុងសំណុំរឿង ០០៤/០១។ អង្គបុរេជំនុំជម្រះបានដោះស្រាយសំណើសុំទាំងបីខាងលើក្នុងរយៈពេល ៦ ថ្ងៃ ទៅ ៣ ខែ បន្ទាប់ពីទទួលបានសំណើទាំងនោះ។ ការឆ្លើយតបរហ័សនេះ ដោយសារអង្គបុរេទទួលបានការជួយជ្រោមជ្រែងបន្ថែមពីការិយាល័យរដ្ឋបាល។ កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/០១ ពេលនេះបានបិទបញ្ចប់ហើយ។

[9] កត់សម្គាល់ថា ដោយយោងទៅលើភាពស្មុគស្មាញ សំណុំរឿង ០០៤ ស្រដៀងគ្នាខ្លាំងទៅនឹងសំណុំរឿង ០០២/០២ ដែលបច្ចុប្បន្ននេះកំពុងរង់ចាំសាលក្រមនៅអង្គជំនុំជម្រះសាលាដំបូង ហើយអង្គជំនុំជម្រះនេះមានចៅក្រមអន្តរជាតិ និងបុគ្គិកធ្វើការលើរឿងក្ដីមួយនោះច្រើនជាងភាគីអន្តរជាតិនៃ ក.ស.ច.ស. ដែលមានសម្រាប់សំណុំរឿងបីទៀតដែលនៅសល់។

23 នៅចុងបញ្ចប់នៃរយៈពេលធ្វើសេចក្តីរាយការណ៍នេះ អង្គបុរេជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ និង ញត្តិស្នើសុំមោឃភាពចំនួន៤ ដែលមួយក្នុងចំណោមនោះត្រូវបានដាក់ចាប់តាំងពីមានការកែប្រែចុង ក្រោយនៃផែនការបញ្ចប់មកម្លេះ៖

ក. ក្នុង*សំណុំរឿង០០៣* ញត្តិស្នើសុំមោឃភាពចំនួន ១។

ខ. នៅក្នុង*សំណុំរឿង ០០៤* ញត្តិស្នើសុំមោឃភាពចំនួន២ និងបណ្តឹងឧទ្ធរណ៍ ១។

24 ទាក់ទិននឹងការបញ្ចប់នីតិវិធី អង្គបុរេជំនុំជម្រះនៅតែមានបំណងចេញសេចក្តីសម្រេចលើបណ្តឹង ឧទ្ធរណ៍ជាសក្តានុពលណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង០០៤ ក្នុងពេល វេលាសមស្រប ដែលបច្ចុប្បន្នត្រូវបានប៉ាន់ប្រមាណចំនួនពីរត្រីមាស គិតចាប់ពីទទួលបានសារណា ជាលាយលក្ខណ៍អក្សរ អាស្រ័យលើលក្ខណៈនៃសេចក្តីសន្និដ្ឋាន បុគ្គលិក និងធនធានបកប្រែភាសា ដែលមានកម្រិត។ ការប៉ាន់ស្មាននាពេលបច្ចុប្បន្ន មានដូចខាងក្រោម៖

ក. នៅក្នុង*សំណុំរឿង ០០៣* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវ បានប៉ាន់ស្មានត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩។

ខ. នៅក្នុង*សំណុំរឿង ០០៤* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវ បានប៉ាន់ស្មានត្រឹមត្រីមាសទី១ ឆ្នាំ២០២០។

គ. នៅក្នុង*សំណុំរឿង ០០៤/០២* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រឹមត្រីមាសទី២ ឆ្នាំ២០១៩។

25 រាល់ការប៉ាន់ស្មានទាំងអស់ក៏អាស្រ័យទៅលើ បុគ្គលិកដែលមាននៅក្នុងអង្គបុរេជំនុំជម្រះ និងការ បកប្រែភាសាបានឆាប់រហ័សនូវសេចក្តីសន្និដ្ឋានរបស់ភាគី និងសេចក្តីសម្រេចនានា ជាបីភាសាផ្លូវការ របស់តុលាការផងដែរ។

26 ចុងក្រោយ ប្រសិនបើមានការដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះក៏នឹងត្រូវការពេលវេលាប្រហែល ៣ ខែ ផងដែរដើម្បីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ក្រោយពេលចេញសាលដីកាលើបណ្តឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

## IV. ផែនការបញ្ចប់សវនាការ

27 តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគ ស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹង រដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សី ទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និង ការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាង កំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះ វិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

28 ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការ ជាក់ស្តែង។ ការជំនុំជម្រះចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះ

សាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខានុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគី ព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដួចផ្ដើមនូវចំណុចជាក់លាក់អំពីសំណាងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្ដីចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបានមុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្ដើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី នឹងសាក្សី និងស្ដាប់នូវការបង្ហាញភ័ស្ដុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្ដុតាងទាំងអស់រួចហើយអង្គជំនុំជម្រះស្ដាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាសម្រេច។ ប្រសិនបើជនជាប់ចោទត្រូវផ្ដន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្រប នៅក្នុងសាលក្រមនោះ។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

ក. **<u>សំណុំរឿង០០២/០២</u>**

29 កិច្ចដំណើរការនីតិវិធីលើភ័ស្ដុតាងបានចាប់ផ្ដើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្ដាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥ បង្ហាញថា ការកំណត់ ៤ថ្ងៃ ក្នុង ១សប្ដាហ៍ ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឱ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់ ៤ថ្ងៃក្នុង ១សប្ដាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្ដី។ សវនាការលើភ័ស្ដុតាង បានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំ ជម្រះបានស្ដាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្ដឹង រដ្ឋប្បវេណីសរុបចំនួន ៦៣ និងអ្នកជំនាញចំនួន៨នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្ដិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើពុទ្ធសាសនិក) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្ដហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្ដិសុខអូរកន្សែង ភ្នំក្រោល និងមន្ទីរសន្ដិសុខស២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង បទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង ជាចុងក្រោយគឺតួនាទីរបស់ជនជាប់ចោទ។

30 ដើម្បីរៀបចំការបិទដំណើរការនីតិវិធី អង្គជំនុំជម្រះបានធ្វើកិច្ចប្រជុំរៀបចំសវនាការនៅខែធ្នូ ឆ្នាំ២០១៦ ដើម្បី ស្ដាប់សារណាពាក់ព័ន្ធនឹង សេចក្ដីសន្និដ្ឋាន និងសេចក្ដីថ្លែងបិទបញ្ចប់ការដេញ ដោលក្នុងចំណោមបញ្ហាដទៃៗទៀត។ ដោយកត់សម្គាល់បញ្ហាចម្បងៗលើកឡើងដោយភាគី ជាពិសេស រយៈពេលវែងខុសពីធម្មតា និងភាពស្មុគស្មាញនៃរឿងក្ដី អង្គជំនុំជម្រះក៏កំណត់កាលបរិច្ឆេទសម្រាប់ដាក់សារណាជំនុំជម្រះស្ថាពរនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងការចាប់ផ្ដើមសេចក្ដីថ្លែងបញ្ចប់ការពិភាក្សាដេញដោលនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។ ក្រោយមក អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគី មានពេលវេលាបន្ថែមមួយសប្ដាហ៍ទៀត ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសារតែការពិនិត្យឡើងវិញ លើប្រតិចារឹកសវនាការរបស់អង្គភាពប្រតិចារឹក កំពុងបន្ដដំណើរការ ដែលប្រការនេះបានបង្កជាផលវិបាកដល់ភាគីក្នុងការពឹងផ្អែកទៅលើកំណត់ហេតុរបស់តុលាការ នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហេតុនេះ ការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានកំណត់ពេលឡើងវិញ និងបានធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ បន្ទាប់ពីនោះមក អង្គជំនុំជម្រះបានផ្អាកសវនាការដើម្បីពិភាក្សាសម្រេច និងរៀបចំសាលក្រមនៅក្នុងរឿងក្ដីនេះ។

31 ការប៉ាន់ស្មានដំបូងទៅលើតម្រូវការពេលវេលាក្នុងការចេញសាលក្រមក្នុងសំណុំរឿង០០២/០២ គឺធ្វើឡើងមុនពេលចាប់ផ្ដើមការជំនុំជម្រះដោយផ្អែកលើបទពិសោធន៍សំណុំរឿង០០២/០១ ដោយពុំទាន់

បានដឹងមានសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកជំនាញ ចំនួនប៉ុន្មាននាក់នឹងត្រូវផ្ដល់សក្ខីកម្ម។ ការប៉ាន់ស្មាននេះ ត្រូវបានកែសម្រួលឡើងវិញនៅក្នុងការកែសម្រួលលើកទី១២ នៃគម្រោងបញ្ចប់ផែនការ ដោយពិចារណាទៅលើការណ៍ដែលថាមានសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្នុងចំនួនទ្វេដងត្រូវបានស្ដាប់សក្ខីកម្មនៅក្នុង សំណុំរឿង ០០២/០២ (សរុបចំនួន ១៨៥ នាក់) លើសសំណុំរឿង០០២/០១ ដែលជាការបង្កើតនូវមូលដ្ឋានភស្ដុតាងធំជាងមុនច្រើន (រួមបញ្ចូលឯកសារប្រមាណ ១០.៨០០) សម្រាប់ការពិចារណា និងវិភាគនៅក្នុងពេលពិភាក្សាសម្រេច និងដំណើរការព្រាងសាលក្រម។ នៅក្នុងដំណាក់កាលរៀបចំសាលក្រម ក្រោយពីបានបញ្ចប់កិច្ចការជុំកំភ្ជួនរួចមក អង្គជំនុំជម្រះកាន់តែមានលទ្ធភាពវាយតម្លៃផលប៉ះពាល់ជាក់ស្ដែង នៃមូលដ្ឋានភស្ដុតាងកាន់តែធំ។ ដោយសាលក្រមជំនុំជម្រះក្នុងសំណុំរឿង០០២/០១ មានចំនួនសរុប ៦៧០ ទំព័រ (រួមទាំងឧបសម្ព័ន្ធ) ហេតុដូច្នេះអង្គជំនុំជម្រះរំពឹងថាសាលក្រមជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ នឹងមានចំនួនលើសពី ២០០០ ទំព័រ ដើម្បីធានាថាបទចោទទាំងអស់ត្រូវបានចាត់ការបានសមស្រប។ ពីមុនអង្គជំនុំជម្រះធ្លាប់ប៉ាន់ស្មានខុសចំពោះពេលវេលាដែលចាំបាច់ក្នុងការវាយតម្លៃ និងប្រជុំពិភាក្សាសម្រេចលើភស្ដុតាងក្នុងចំនួនដ៏ច្រើនសន្ធឹកនៃរឿងក្ដីដ៏ស្មុគស្មាញនេះ។

32 រយៈពេលគ្រោងទុកសម្រាប់ចេញសាលក្រម បានធ្វើឱ្យការមានចំនួនបុគ្គលិកពេញលេញនៅក្នុងអង្គជំនុំជម្រះសាលាដំបូង កាន់តែមានសារៈសំខាន់។ ការធ្វើជាតួបន្ទីយកម្មមុខតំណែងនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ជាលទ្ធផលនាំឱ្យអង្គជំនុំជម្រះខ្វះមន្ត្រីច្បាប់អន្តរជាតិម្នាក់។ ជាងនេះទៀតអង្គជំនុំជម្រះសាលាដំបូង បានបន្តទទួលរងនូវផលអវិជ្ជមាននៃការចាកចេញរបស់បុគ្គលិក បូករួមជាមួយភាពអូសបន្លាយជាប្រព័ន្ធក្នុងដំណើរការជ្រើសរើសបុគ្គលិកអង្គការសហប្រជាជាតិ។ ដោយមូលហេតុពេលវេលាដែលតម្រូវ ក្នុងការជ្រើសរើស និង ចាត់តាំងបុគ្គលិក (រយៈពេលអប្បបរមា៥ខែ) នៅដំណាក់កាលនេះអង្គជំនុំជម្រះនឹងពឹងផ្អែកទាំងស្រុងលើបុគ្គលិកប្រឹក្សា ដើម្បីបំពេញមុខតំណែងទំនេរបច្ចុប្បន្ន និងអនាគត។ អង្គជំនុំជម្រះនឹងត្រូវការការគាំទ្រពេញលេញពីផ្នែករដ្ឋបាល ដើម្បីពន្លឿនដំណើរការនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះធ្វើការកត់សម្គាល់ត្រង់ចំណុចនេះថា ការឈប់ពីការងាររបស់បុគ្គលិក ត្រូវបានរំពឹងថានឹងកើតឡើងដោយសារស្ថានភាពហិរញ្ញវត្ថុមិនច្បាស់លាស់របស់សាលាក្ដី កិច្ចសន្យារយៈពេលខ្លី និង ការហៀបនឹងបញ្ចប់សាលក្រមសំណុំ រឿង០០២/០២ ដែលកាន់តែបានជំរុញឲ្យបុគ្គលិកស្វែងរកការងាររយៈពេលវែង និងមានភាពច្បាស់លាស់។

33 អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ប្រាប់ការិយាល័យរដ្ឋបាលពីមុនមក អំពីបញ្ហាពាក់ព័ន្ធនឹងការបញ្ចប់ការបកប្រែឲ្យបានទាន់ពេលវេលា ដែលអាចពន្យារពេលបន្តទៀតក្នុងការចេញសាលក្រម។ ក្នុងន័យនេះ អង្គជំនុំជម្រះថ្មីៗនេះបានទទួលការធានាថា សមត្ថភាពបកប្រែភាសា (ពីអង់គ្លេសទៅខ្មែរ) នឹងត្រូវបានបង្កើន ដើម្បីឱ្យអង្គជំនុំជម្រះអាចបំពេញតាមកាលបរិច្ឆេទកំណត់របស់ខ្លួន។ ដោយហេតុថាកិច្ចការបកប្រែមានទំហំធំ និងក្នុងរយៈពេលខ្លី អង្គជំនុំជម្រះមិនជឿជាក់ថានឹងអាចចេញសាលក្រមជា៣ភាសាដំណាលគ្នាឡើយ។ អង្គជំនុំជម្រះនឹងផ្ដោតសំខាន់លើសំណៅជាភាសាអង់គ្លេស និងខ្មែរ ដើម្បីធានាថាសាលក្រមនឹងត្រូវចេញក្នុងពេលសមស្រប។ ទន្ទឹមគ្នានេះដែរ អង្គជំនុំជម្រះក៏នឹងធ្វើឲ្យមានការរីកចម្រើនលើសំណៅបកប្រែជាភាសាបារាំង តាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយកត់សម្គាល់ថាសាលក្រមជាភាសាបារាំងអាចប៉ះពាល់ដល់កាលបរិច្ឆេទកំណត់នៃបណ្ដឹងសាទុក្ខ។

34 អង្គជំនុំជម្រះសាលាដំបូងបន្តពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។ សម្បទារបស់ជនជាប់ចោទក្នុងការបន្តចូលរួមសវនាការត្រូវបានវាយតម្លៃនៅចុងខែមករា ឆ្នាំ២០១៨ ហើយពិនិត្យឃើញថាជនជាប់ចោទទាំងពីរមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ របាយការណ៍វេជ្ជសាស្ត្រកត់សម្គាល់អំពីជំងឺមួយចំនួនដែលជនជាប់ចោទមាន ហើយបានផ្ដល់អនុសាសន៍ឲ្យបន្តវាយតម្លៃទៅលើមុខងារសតិបញ្ញារបស់ជនជាប់ចោទរៀងរាល់ត្រីមាស។

35 ដោយពិចារណាទៅលើកត្តាទាំងឡាយខាងលើនេះ អង្គជំនុំជម្រះវាយតម្លៃថាជាការចាំបាច់គឺត្រូវពន្យារកាលកំណត់នៃការចេញសាលក្រមចំនួន១ត្រីមាស ពោលគឺនឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៨។ ដោយកត់សម្គាល់ថា ចៅក្រមអន្តរជាតិម្នាក់ក្នុងចំណោមចៅក្រមអន្តរជាតិទាំងអស់ត្រូវត្រឡប់ទៅកាន់យុត្តាធិការជាតិរបស់ខ្លួនវិញ នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨ ដូច្នេះប្រសិនបើចាំបាច់ ក្រោយពេលបញ្ចប់កិច្ចប្រជុំពិភាក្សាសម្រេច អង្គជំនុំជម្រះនឹងពិចារណាចេញសាលក្រមផ្ទាល់មាត់ ក្នុងទម្រង់សង្ខេបក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ដោយចេញសាលក្រមជាលាយលក្ខណ៍អក្សរមានសំអាងហេតុពេញលេញតាមក្រោយ។ សាលក្រមជាលាយលក្ខណ៍អក្សរនឹងចេញជាភាសាខ្មែរ និងអង់គ្លេសជាមុនសិន ហើយសំណៅបកប្រែជាភាសាបារាំង នឹងចេញតាមក្រោយយ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន។ សមត្ថភាពរបស់អង្គជំនុំជម្រះក្នុងការអនុវត្តឱ្យបានសម្រេចតាមកាលបរិច្ឆេទកំណត់នេះ នឹងបន្តពឹងផ្អែកលើអង្គភាពគាំទ្រដទៃៗទៀត ដែលនៅតែមានបុគ្គលិកពេញលេញ ហើយអង្គជំនុំជម្រះក៏នៅតែមានចំនួនបុគ្គលិកពេញលេញដែរ។

### ខ. *សំណុំរឿង០០៣ និង សំណុំរឿង០០៤*

36 លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ បើមិនដូច្នោះទេ យើងមិនអាចស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបានឡើយ។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ**

### ក. *សំណុំរឿង០០២/០២*

37 អង្គជំនុំជម្រះតុលាការកំពូលព្យាករនៅពេលនេះថា បណ្តឹងសាទុក្ខមួយ (ច្រើន) ប្រសិនបើដាក់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ នឹងយ៉ាងហោចណាស់ត្រូវការពេលវេលា និងធនធាន ដូចគ្នាក្នុងសំណុំរឿង០០២/០១ ដែរ។ រហូតទាល់តែចេញសាលក្រមក្នុងសំណុំរឿង០០២/០២ ទើបភាគីមានលទ្ធភាពដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងនោះ ដែលត្រូវតែសម្រេចនៅក្នុងរយៈពេលបីខែកំណត់ដោយច្បាប់ ដែលអាចពន្យារពេលបួនខែក្នុងករណីពិសេស។"

### ខ. <u>**សំណុំរឿង០០៣ និងសំណុំរឿង០០៤**</u>

38 ប្រសិនបើសំណុំរឿង០០៣ និង/ឬ ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងសាទុក្ខភ្លាមៗ ឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលត្រូវការក្នុងការសម្រេចលើបណ្តឹងសាទុក្ខណានៃសំណុំរឿងពាក់ព័ន្ធ។

## VI. **សេចក្តីសន្និដ្ឋាន**

39 ព្រឹត្តិការណ៍សំខាន់មួយត្រូវបានសម្រេចក្នុងសំណុំរឿង ០០៤/០១ ក្នុងអំឡុងពេលត្រីមាសនេះ ដោយមានសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹង អ៊ឹម ចែម ដែលមានសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្កល់ ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត។ កិច្ចដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿងនេះពេលនេះបានបិទហើយ។

40 សម្រាប់ឆ្នាំ២០១៨ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ចំនួនមួយក្នុងសំណុំរឿង០០២/០២ គឺ (i) ការចេញសាលក្រម។ ចំពោះសំណុំរឿង ០០៣ និង ០០៤/០២ រំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួនពីរ គឺ (ii) ការចេញដីកាដំណោះស្រាយសម្រាប់សំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

41 នៅឆ្នាំ២០១៩ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួនមួយ ក្នុងសំណុំរឿង ០០២/០២ គឺ (iv) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខណាមួយប្រឆាំងនឹងសាលក្រម។ ព្រឹត្តិការណ៍សំខាន់មួយក៏នឹងសម្រេចបានដែរក្នុងសំណុំរឿង ០០៤ គឺ (v) ការចេញដីកាដំណោះស្រាយ ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។ ជាងនេះទៀត ព្រឹត្តិការណ៍សំខាន់ចំនួនពីរនឹងសម្រេចបាន ដោយសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុង (vi) សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និង (vii) សំណុំរឿង ០០៣ ពាក់ព័ន្ធនឹង មាស មុត។

42 នៅឆ្នាំ២០២០ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ពីរ គឺ (viii) ការចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ដោយមានសេចក្ដីសម្រេចពីអង្គបុរេជំនុំជម្រះ និង (xi) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

43 ក្នុងករណីដែលសំណុំរឿង០០៣ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករនៅពេលនោះ។

44 ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករ មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ១៧ - ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨

| សំណុំរឿង | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
| សំណុំរឿង០០២/០២ | | (ក) | | ដំណាក់កាលជំនុំជម្រះ | | | | (ខ) | (គ) | | | បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម | | | | (ឃ) |

(ក) សេចក្ដីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល
(ខ) សាលក្រម
(គ) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម
(ឃ) សាលដីកា

| សំណុំរឿង | ២០១៧ ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ២០១៨ ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ | ២០១៩ ត្រីមាស១ | ត្រីមាស២ | ត្រីមាស៣ | ត្រីមាស៤ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សំណុំរឿង០០៣<br>មាស មុត | | | | | | | | (ង) | បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ | | (ច) | |
| សំណុំរឿង ០០៤/០២<br>អោ អាន | | | | | | | (ង) | | | (ច) | | |
| សំណុំរឿង ០០៤<br>យឹម ទិត្យ | | | | | | | | | (ង) | | | (ច) |

(ង) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០២
(ច) សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០២